**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**
លេខ : ៤៦០១ មស.សង៣

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបោះពុម្ពតារាងទូទាត់បៀវត្ស អាណត្តិបើកប្រាក់ និងការបើកផ្តល់បៀវត្ស ជូនមន្ត្រីរាជការស៊ីវិលសម្រាប់ខែ មករា ឆ្នាំ ២០១៨

យោងសារាចរលេខ ០១ សរ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៤ ស្តីពីការកំណត់នីតិវិធីសម្រាប់ការបើកផ្តល់បៀវត្សជូនមន្ត្រីរាជការស៊ីវិល ។

ក្រសួងមុខងារសាធារណៈ មានកិត្តិយសសូមគោរពជម្រាបជូន សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ឯកឧត្តម លោកជំទាវអភិបាលនៃគណៈអភិបាល រាជធានី ខេត្ត និងលោក លោកស្រីប្រធានមន្ទីរ អង្គភាពជំនាញរាជធានី ខេត្តមេត្តាជ្រាបថា ក្នុងគោលបំណងចូលរួមអនុវត្តឱ្យបានសម្រេចនូវខ្លឹមសារនៃសារាចរដូចមានយោងខាងលើ និងដើម្បីរួមចំណែកក្នុងការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការជំរុញបៀវត្សឱ្យមានប្រសិទ្ធភាព ក្រសួងមុខងារសាធារណៈ សូមដាក់ចេញនូវសេចក្តីជូនដំណឹងសម្រាប់សហការអនុវត្តដូចខាងក្រោម៖

- សម្រាប់ការបើកផ្តល់បៀវត្សប្រចាំខែ**មករា** ឆ្នាំ២០១៨ ក្រសួងមុខងារសាធារណៈ សូមស្នើសុំគ្រប់ក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត មន្ទីរ អង្គភាពជំនាញ រាជធានី ខេត្តពាក់ព័ន្ធ ត្រូវយកសំណុំឯកសារបៀវត្សប្រចាំខែ**មករា ឆ្នាំ២០១៨** របស់មន្ត្រីរាជការស៊ីវិល មកក្រសួងមុខងារសាធារណៈ ឬមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត ដោយពុំចាំបាច់ធ្វើការប្រែប្រួលស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសារឡើយ ។
- ក្រសួងមុខងារសាធារណៈ សូមស្នើសុំក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត មន្ទីរ អង្គភាពជំនាញ រាជធានី ខេត្ត ត្រូវយកសំណុំឯកសារបៀវត្សប្រចាំខែ**មករា** ឆ្នាំ២០១៨ របស់មន្ត្រីរាជការស៊ីវិល មកក្រសួងមុខងារសាធារណៈ ឬមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត ឱ្យបានយ៉ាងយូរត្រឹមសប្តាហ៍ទី៣ ខែ**ធ្នូ** ឆ្នាំ២០១៧ ។
- ក្រសួងមុខងារសាធារណៈ នឹងរៀបចំបោះពុម្ពតារាងទូទាត់បៀវត្សប្រចាំខែ**មករា** ឆ្នាំ២០១៨ ដោយផ្អែកលើទិន្នន័យ ដែលមានក្នុងតារាងទូទាត់បៀវត្សរបស់មន្ត្រីរាជការស៊ីវិលប្រចាំខែ**ធ្នូ** ឆ្នាំ២០១៧ ជាគោល និងធ្វើការរៀបចំទិន្នន័យមួយចំនួនទៀត ជាស្វ័យប្រវត្តិទៅតាមគោលការណ៍ថ្មីរបស់រាជរដ្ឋាភិបាល ។

ក្រសួងមុខងារសាធារណៈ សង្ឃឹមថា សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ឯកឧត្តម លោកជំទាវអភិបាលនៃគណៈអភិបាល រាជធានី ខេត្ត និងលោក លោកស្រីប្រធានមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត នឹងចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះ តាមការគួរ ។

ថ្ងៃ ពុធ ១០រោច ខែ មិគសិរ ឆ្នាំ រកា ព.ស ២៥៦១
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ធ្នូ គ.ស ២០១៧

**រដ្ឋមន្ត្រី**

**ពេជ្រ ប៊ុនធិន**

**ចម្លងជូន៖**
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- មន្ទីរនិងអង្គភាពជំនាញរាជធានី ខេត្ត
- ឯកសារ-កាលប្បវត្តិ